Embassy of Japan

ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៦

សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់។

ទូលបង្គំ-ខ្ញុំបាទសូមសម្តែងគារវកិច្ចគោរព និងជំរាបជូនពីការបញ្ចប់បេសកកម្មរបស់ទូលបង្គំ-ខ្ញុំបាទជាឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំប្រទេសកម្ពុជា។

ទូលបង្គំ-ខ្ញុំបាទ សូមសម្តែងនូវអំណរព្រះគុណ និងអរគុណអស់ពីដួងចិត្ត ថ្វាយ និងជូនចំពោះ សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ ដែលតែងតែប្រទាន និងផ្តល់ការជួយជ្រោមជ្រែង និង គាំទ្រាល់សកម្មភាពរបស់ទូលបង្គំ-ខ្ញុំបាទជាឯកអគ្គរាជទូតរបស់ប្រទេសជប៉ុនប្រចាំប្រទេសកម្ពុជាក្នុងរយៈពេលជាង៣ឆ្នាំកន្លងមកនេះ។

ក្នុងរយៈពេលបំពេញបេសកកម្មការទូតនៅកម្ពុជាចាប់ពីខែមិនា ឆ្នាំ២០១៣ រហូតដល់ខែកញ្ញា ឆ្នាំ២០១៦ នេះ ទូលបង្គំ-ខ្ញុំបាទបានព្យាយាមយ៉ាងអស់ពីសមត្ថភាព។ ទោះបីជាកិច្ចការដែលទូលបង្គំ-ខ្ញុំបាទបានធ្វើនៅមានកម្រិតក្តី ប៉ុន្តែទូលបង្គំ-ខ្ញុំបាទបានឃើញពីការរីកចម្រើនជាបន្តបន្ទាប់នៃទំនាក់ទំនងទ្វេភាគីរវាងជប៉ុននិងកម្ពុជា ដោយមានការចូលរួមយ៉ាងច្រើនពីសំណាក់ប្រជាជននៃប្រទេសទាំងពីរ។ ទូលបង្គំ-ខ្ញុំបាទពិតជាមានក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានបំពេញភារកិច្ចជាឯកអគ្គរាជទូត ស្របពេលដែលទំនាក់ទំនងប្រទេសយើងទាំងពីរកំពុងមានការរីកចម្រើនយ៉ាងខ្លាំង។

No.194, Moha Vithei Preah Norodom, Phnom Penh, Cambodia ( P.O.BOX21, Phnom Penh)
Tel: 855 (23) 217 161~4, Fax: 855 (23) 216 162

ក្នុងឱកាសបេសកកម្មរបស់ទូលបង្គំ-ខ្ញុំបាទកន្លងមកនេះ ទូលបង្គំ-ខ្ញុំបាទបានជួបជាមួយប្រជាជនកម្ពុជា និងបណ្ដាភ្ញៀវមកពីប្រទេសជប៉ុនជាច្រើន ព្រមទាំងបានចូលរួមក្នុងពិធីចុះហត្ថលេខា ពិធីសម្ពោធបើកការដ្ឋាន និងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នៃគម្រោងសហប្រតិបត្តិការនៃប្រទេសយើងទាំងពីរជាច្រើនទៀតដែលមិនអាចរៀបរាប់អស់។ ចំពោះទំនាក់ទំនងជាមួយក្រុមហ៊ុនជប៉ុនវិញ ទូលបង្គំ-ខ្ញុំបាទបានចូលរួម ពិធីសម្ពោធកាត់ខ្សែបូរណ៍ក្នុងពិធីសម្ពោធក្រុមហ៊ុនជប៉ុននានានៅកម្ពុជាជាច្រើនផងដែរ។ព្រឹត្តិការណ៍សំខាន់ៗមួយចំនួនមានដូចជា ពិធីសម្ពោធផ្សារទំនើបអ៊ីអន ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវស្ពានត្សឹបាសា និងថ្មីៗនេះគឺការសម្ពោធនូវជើងហោះហើរត្រង់រវាងជប៉ុន និងកម្ពុជារបស់ក្រុមហ៊ុនអាកាសចរណ៍ANA។ សកម្មភាពទាំងអស់នេះបានឆ្លុះបញ្ចាំងពីការរីកចម្រើននៃទំនាក់ទំនងទ្វេភាគីរបស់ប្រទេសយើងទាំងពីរ។ ក្ដីរីករាយដ៏ធំបំផុតរបស់ទូលបង្គំ-ខ្ញុំបាទគឺបានឃើញពីទំនាក់ទំនងជប៉ុន-កម្ពុជា រីកចម្រើនដុះដាលយ៉ាងទូលំទូលាយ និងស៊ីជម្រៅក្នុងរយៈពេលនៃបេសកកម្មការទូតនៅកម្ពុជា ព្រមទាំងកំណើននៃវត្តមានជប៉ុននៅកម្ពុជា និងការរួមចំណែករបស់ជប៉ុនក្នុងការជួយអភិវឌ្ឍប្រទេសកម្ពុជា។

នៅពេលដែលបេសសកម្មការទូតរបស់ទូលបង្គំ-ខ្ញុំបាទត្រូវបានបញ្ចប់នៅកម្ពុជា ទូលបង្គំ-ខ្ញុំបាទនៅតែនឹកអាល័យដល់ប្រទេសកម្ពុជា និង ប្រជាជនកម្ពុជាទាំងអស់។ ប្រជាជនជប៉ុនជាច្រើនតែងតែរំលឹកឡើងពីបទពិសោធន៍ក្រោយសង្គ្រាមរបស់ខ្លួន ពេលដែលឃើញកម្ពុជាកំពុងប្រឈមបញ្ហាលំបាកក្រោយសង្គ្រាម។ នេះគឺជាមូលហេតុមួយធ្វើឲ្យប្រជាជនជប៉ុនមានអារម្មណ៍ជិតដានខ្លាំងជាមួយនិងកម្ពុជា ហើយក៏ចាប់ផ្ដើមគិតថាតើខ្លួនអាចចូលរួមជួយអ្វីបានខ្លះដល់កម្ពុជា។ ប្រទេសជប៉ុនបានបញ្ចប់សង្គ្រាមរយៈពេល៧១ឆ្នាំហើយ ចំណែកប្រទេសកម្ពុជាវិញ មិនទាន់ឆ្លងកាត់ពេលវេលាច្រើនឆ្នាំដូចប្រទេសជប៉ុនទេ។ ទូលបង្គំ-ខ្ញុំបាទ មានបំណងប្រាថ្នាអោយប្រទេសកម្ពុជាអាចដោះស្រាយបញ្ហាដែលនៅសេសសល់ពីសង្គ្រាមដ៏រ៉ាំរ៉ៃ និងបោះជំហានបន្តិចម្ដងៗឆ្ពោះទៅកាន់ការរួបរួមគ្នារវាងប្រជាជន និងប្រជាជន និងមានស្ថិរភាពជានិរន្តរ៍ រួមជាមួយនិងការអភិវឌ្ឍទាំងសេដ្ឋកិច្ច សង្គម និងនយោបាយ។

ឯកឧត្តម ឯកអគ្គរាជទូតថ្មីនឹងអញ្ជើញមកដល់ ក្រោយពីទូលបង្គំ-ខ្ញុំបាទបញ្ចប់បេសកកម្មការទូតនៅកម្ពុជា។ សូមសម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ បន្តប្រទាន និងផ្តល់ការជួយគាំទ្រចំពោះសកម្មភាពរបស់ឯកឧត្តម ឯកអគ្គរាជទូតថ្មី ដូចដែលទូលបង្គំ-ខ្ញុំបាទធ្លាប់ទទួលបានកន្លងមក។

ជាចុងក្រោយទូលបង្គំ-ខ្ញុំបាទសូមថ្លែងអំណរព្រះគុណ និងអរគុណ និងសូមថ្វាយព្រះពរ និងជូនពរបវរមហាប្រសើរ សូមសម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រជាជនកម្ពុជាទាំងអស់ប្រកបដោយសុខភាពល្អបរិបូរណ៍ និងទទួលបានតែសុខសុភមង្គលជានិរន្តរ៍។

**គូម៉ាម៉ារូ យូជិ**

**ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពជប៉ុន**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**